OREGON PROVIDER Time Capture

# ការណែនាំអំពីការកំណត់អ្នកប្រើប្រាស់ 2.0

OR PTC DCI

កំណែ 2.0

## មាតិកា


សេចក្តីប្រកាសបដិសេធ ...... 2

ការកំណត់របស់អ្នកប្រើប្រាស់ ...... 2

ផ្លាស់ប្តូរពាក្យសម្ងាត់ ...... 2

ភ្លេចពាក្យសម្ងាត់ ...... 4

កំណត់ពាក្យសម្ងាត់ឡើងវិញ ...... 7

បន្ថែមលេខសម្គាល់ផ្ទាល់ខ្លួន ...... 9

ផ្លាស់ប្តូរលេខសម្គាល់ផ្ទាល់ខ្លួន ...... 10

ផ្លាស់ប្តូរសំណួរសុវត្ថិភាព ...... 12

ផ្លាស់ប្តូរអ៊ីម៉ែល ...... 13

ផ្ទៀងផ្ទាត់លេខទូរសព្ទចល័ត ...... 15

ផ្លាស់ប្តូរឈ្មោះអ្នកប្រើប្រាស់ ...... 18

## សេចក្តីប្រកាសបដិសេធ

ខ្លឹមសារដែលរកឃើញនៅក្នុងឯកសារនេះមានគោលបំណងសម្រាប់អ្នកប្រើប្រាស់ OR PTC DCI ទាំងអស់។ រូបថតអេក្រង់នៅក្នុងឯកសារនេះបានមកពីទស្សនៈរបស់អ្នកផ្តល់សេវា ប៉ុន្តែជំហាននានាគឺដូចគ្នាសម្រាប់ប្រភេទអ្នកប្រើប្រាស់ផ្សេងទៀតទាំងអស់។

## ការកំណត់របស់អ្នកប្រើប្រាស់

នៅពេលបានចូលក្នុងផតថលគេហទំព័រ OR PTC DCI រួច អ្នកអាចផ្លាស់ប្តូរពាក្យសម្ងាត់ លេខសម្គាល់ផ្ទាល់ខ្លួន សំណួរសុវត្ថិភាព អ៊ីមែល និងឈ្មោះអ្នកប្រើប្រាស់របស់អ្នកបាន។ អ្នកក៏អាចផ្ទៀងផ្ទាត់លេខទូរសព្ទរបស់អ្នកបានផងដែរ។ ប្រសិនបើអ្នកមិនអាចចូលក្នុងផតថលគេហទំព័រ OR PTC DCI បានទេ អ្នកអាចកំណត់ពាក្យសម្ងាត់របស់អ្នកឡើងវិញ ឬស្នើសុំជំនួយក្នុងការកំណត់វាឡើងវិញបាន។ ប្រសិនបើអ្នកចង់ធ្វើបច្ចុប្បន្នភាពព័ត៌មានណាមួយដែលមិនមាននៅក្នុងការណែនាំនេះទេ សូមទាក់ទងទៅការិយាល័យក្នុងតំបន់របស់អ្នក (ប្រសិនបើអ្នក គឺជាសមាជិកបុគ្គលិក សូមទាក់ទងទៅក្រុមជំនួយ PTC)។

## ផ្លាស់ប្តូរពាក្យសម្ងាត់

អ្នកប្រហែលជាចង់ផ្លាស់ប្តូរពាក្យសម្ងាត់ OR PTC DCI របស់អ្នក។

**ចំណាំ៖** ដើម្បីផ្លាស់ប្តូរពាក្យសម្ងាត់របស់អ្នកដោយប្រើប្រាស់វិធីសាស្ត្រនេះ អ្នកត្រូវតែដឹងពីពាក្យសម្ងាត់បច្ចុប្បន្នរបស់អ្នក។

ដើម្បីផ្លាស់ប្តូរពាក្យសម្ងាត់របស់អ្នក៖

1. ជ្រើសរើសរូបតំណាងមនុស្សនៅជាប់នឹងឈ្មោះអ្នកប្រើប្រាស់របស់អ្នក។
2. ជ្រើសរើស ការកំណត់។



3. បញ្ចូលពាក្យសម្ងាត់បច្ចុប្បន្ន។
4. បញ្ចូលពាក្យសម្ងាត់ថ្មីទៅតាមលក្ខណៈវិនិច្ឆ័យនៃពាក្យសម្ងាត់។
    a. ត្រូវតែមានយ៉ាងតិចណាស់ 10 តួអក្សរ។
    b. ត្រូវតែមានអក្សរធំ អក្សរតូច លេខ និងតួអក្សរពិសេស 1។
    c. មិនត្រូវមានតួរអក្សរដដែលច្រើនជាងពីរបន្តបន្ទាប់គ្នាទេ។
    d. ត្រូវតែខុសពីពាក្យសម្ងាត់ 24 ចុងក្រោយរបស់អ្នក។
5. វាយបញ្ចូលពាក្យសម្ងាត់ថ្មីរបស់អ្នកម្តងទៀត។
6. ជ្រើសរើសពាក្យ ផ្លាស់ប្តូរពាក្យសម្ងាត់ ដើម្បីបញ្ចប់ការផ្លាស់ប្តូរ។




7. ជ្រើសរើសពាក្យ បាទ/ចាស ដើម្បីបញ្ជាក់ការផ្លាស់ប្តូរពាក្យសម្ងាត់។



8. បន្ទាប់មកអ្នកនឹងឃើញផ្ទាំងពណ៌បៃតងដែលបង្ហាញថា "ពាក្យសម្ងាត់ត្រូវបានផ្លាស់ប្តូរដោយជោគជ័យ" ឥឡូវនេះ ពាក្យសម្ងាត់របស់អ្នកត្រូវបានធ្វើបច្ចុប្បន្នភាពរួចហើយ ហើយមិនត្រូវការសកម្មភាពបន្ថែមទៀតទេ។
9. ជ្រើសរើស ទំព័រដើម ឬរូបតំណាង OR PTC DCI ដើម្បីត្រឡប់ទៅអេក្រង់ដើមវិញ។




## ភ្លេចពាក្យសម្ងាត់

ប្រសិនបើអ្នកបានភ្លេចពាក្យសម្ងាត់របស់អ្នក ហើយមានអ៊ីមែលនៅលើឯកសារ អ្នកអាចកំណត់ពាក្យសម្ងាត់ផ្ទាល់ខ្លួនរបស់អ្នកឡើងវិញបាន។

ដើម្បីកំណត់ពាក្យសម្ងាត់របស់អ្នកឡើងវិញ៖

1. ជ្រើសរើសពាក្យ "ភ្លេចពាក្យសម្ងាត់របស់អ្នក?" ប៊ូតុងនៅលើអេក្រង់ចូល។
2. បញ្ចូលអាសយដ្ឋានអ៊ីមែលទៅក្នុងកន្លែងបំពេញអ៊ីមែល។
3. ចុចប៊ូតុង ផ្ញើអ៊ីមែលកំណត់ឡើងវិញ។






4. បន្ទាប់មកអ្នកនឹងឃើញការជូនដំណឹងបញ្ជាក់។
   ចូលទៅអ៊ីមែលរបស់អ្នកនៅលើឯកសារនៅក្នុង OR PTC DCI។




5. បើកអ៊ីមែលកំណត់ពាក្យសម្ងាត់ឡើងវិញពី orptcsupport@dcisoftware.com។
6. ចុចពាក្យ កំណត់ពាក្យសម្ងាត់ឡើងវិញ។




**ចំណាំ៖**
ប្រសិនបើអ្នកមិនបានទទួលអ៊ីមែលនេះ៖

- ដំបូង សូមពិនិត្យថតសារឥតបានការរបស់អ្នក។
- បន្ទាប់មក ទូរសព្ទទៅការិយាល័យកម្មវិធីរបស់អ្នកដើម្បីប្រាកដថាអាសយដ្ឋានអ៊ីមែលគឺត្រឹមត្រូវនៅលើឯកសារសម្រាប់អ្នក។

7. ដើម្បីកំណត់ពាក្យសម្ងាត់ឡើងវិញ អ្នកត្រូវតែផ្តល់៖
    a. ចម្លើយចំពោះសំណួរសុវត្ថិភាពរបស់អ្នក **ឬ**
    b. លេខលេខសន្តិសុខសង្គម 4 ខ្ទង់ចុងក្រោយរបស់អ្នក និង ថ្ងៃខែឆ្នាំកំណើតរបស់អ្នក។
8. បញ្ចូលការឆ្លើយតបមួយទៅនឹងជម្រើសមួយក្នុងចំណោមពីរ រួចចុច ផ្ទៀងផ្ទាត់។




**ចំណាំ៖** ជម្រើស ខ ប្រហែលជាមិនមាននោះទេ ប្រសិនបើ OR PTC DCI មិនមានព័ត៌មានចាំបាច់នៅលើឯកសារសម្រាប់អ្នក។

9. បញ្ចូលពាក្យសម្ងាត់ថ្មីដែលអ្នកចង់ប្រើ។
10. បញ្ចូលពាក្យសម្ងាត់ថ្មីឡើងវិញ។
11. ជ្រើសរើសប៊ូតុង កំណត់ឡើងវិញ ដើម្បីបញ្ចប់ការកំណត់ពាក្យសម្ងាត់ឡើងវិញ។




**ចំណាំ៖** ជ្រើសរើសរូបតំណាង "i" ពណ៌ខ្មៅ ដើម្បីបង្ហាញលក្ខខណ្ឌតម្រូវនៃពាក្យសម្ងាត់។

12. ចុច បាទ/ចាស ដើម្បីបញ្ជាក់ពាក្យសម្ងាត់ថ្មី។ អ្នកនឹងត្រូវត្រឡប់ទៅអេក្រង់ចូល OR PTC DCI វិញ។ បញ្ចូលឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់ថ្មីរបស់អ្នកដើម្បីចូល។




**ចំណាំ៖** បុគ្គលិកគួរតែអ៊ីមែលទៅក្រុមជំនួយ PTC តាម PTC.Support@odhsoha.oregon.gov ។ បុគ្គលិកមិនត្រូវទាក់ទងទៅការិយាល័យផ្តល់ព័ត៌មាន DCI ទេ។

## កំណត់ពាក្យសម្ងាត់ឡើងវិញ

ប្រសិនបើអ្នកមិនអាចផ្ទៀងផ្ទាត់ខ្លួនឯងដោយប្រើប្រាស់តំណភ្ជាប់ភ្លេចពាក្យសម្ងាត់បានទេ សូមទាក់ទងទៅការិយាល័យផ្តល់ព័ត៌មាន DCI តាមលេខ 855-565-0155 ឬការិយាល័យក្នុងតំបន់របស់អ្នក ដើម្បីស្នើសុំការកំណត់ពាក្យសម្ងាត់ឡើងវិញ។

នៅពេលពាក្យសម្ងាត់បានកំណត់ឡើងវិញរួចរាល់ហើយ សូមអនុវត្តជំហានទាំងនេះ៖

1. បើកអ៊ីមែលកំណត់ពាក្យសម្ងាត់ឡើងវិញពី orptcsupport@dcisoftware.com ហើយជ្រើសរើសប៊ូតុង កំណត់ពាក្យសម្ងាត់ឡើងវិញ ដើម្បីដំណើរការផតថលគេហទំព័រ OR PTC DCI។

**ចំណាំ៖** ប្រសិនបើអ្នកមិនបានទទួលអ៊ីមែលទេ៖

- ដំបូង សូមពិនិត្យថតសារឥតបានការរបស់អ្នក។
- បន្ទាប់មក ទូរសព្ទទៅការិយាល័យក្នុងតំបន់របស់អ្នក ដើម្បីប្រាកដថា អាសយដ្ឋានអ៊ីមែលត្រឹមត្រូវគឺនៅលើឯកសារសម្រាប់អ្នកនៅក្នុង OR PTC DCI។



2. បញ្ចូលពាក្យសម្ងាត់ថ្មីដែលអ្នកចង់ប្រើ។
3. បញ្ចូលពាក្យសម្ងាត់ថ្មីឡើងវិញ។
4. ជ្រើសរើសប៊ូតុង កំណត់ឡើងវិញ ដើម្បីបញ្ចប់ការកំណត់ពាក្យសម្ងាត់ឡើងវិញ។
5. ជ្រើសរើស បាទ/ចាស ដើម្បីបញ្ជាក់ការកំណត់ពាក្យសម្ងាត់ឡើងវិញ។







**ចំណាំ៖** ជ្រើសរើសរូបតំណាង "i" ពណ៌ខ្មៅ ដើម្បីបង្ហាញលក្ខខណ្ឌតម្រូវនៃពាក្យសម្ងាត់។

នៅពេលអ្នកចូលក្នុង OR PTC DCI លើកក្រោយ អ្នកនឹងត្រូវបាននាំឱ្យធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតនៃសុវត្ថិភាពរបស់អ្នក។

1. ជ្រើសរើសសំណួរសុវត្ថិភាពថ្មី។
2. បញ្ចូលចម្លើយសុវត្ថិភាពថ្មី។
3. ជ្រើសរើស រក្សាទុក ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតនៃសុវត្ថិភាព។

**ចំណាំ៖**
ប្រសិនបើអ្នក**មិន**ប្រើប្រាស់លេខសម្គាល់ផ្ទាល់ខ្លួនទេ ការបញ្ចប់ជំហានទី 3 បញ្ចប់ការកំណត់ពាក្យសម្ងាត់ឡើងវិញ។ ប្រសិនបើអ្នក**ពិតជា**ប្រើប្រាស់លេខសម្គាល់ផ្ទាល់ខ្លួន នោះអ្នកត្រូវតែបញ្ចូលលេខសម្គាល់ផ្ទាល់ខ្លួនថ្មី (សូមមើលបន្ថែមលេខសម្គាល់ផ្ទាល់ខ្លួនសម្រាប់ការណែនាំ)។



## បន្ថែមលេខសម្គាល់ផ្ទាល់ខ្លួន

ប្រសិនបើអ្នកទាក់ទៅការិយាល័យផ្តល់ព័ត៌មានរបស់ DCI ឬក្រុមជំនួយ PTC សម្រាប់ជំនួយពាក្យសម្ងាត់ ពួកគេទំនងជានឹងកំណត់គណនីរបស់អ្នកឡើងវិញ។ ការធ្វើបែបនេះតម្រូវឱ្យអ្នកបន្ថែមលេខសម្គាល់ផ្ទាល់ខ្លួនថ្មី។
អ្នកក៏ប្រហែលជាចង់បន្ថែម/ផ្លាស់ប្តូរលេខសម្គាល់ផ្ទាល់ខ្លួនរបស់អ្នកដោយសារតែវាចាំបាច់សម្រាប់ទូរសព្ទលើតុ OR PTC DCI ផងដែរ។

1. ជ្រើសរើសរូបតំណាងមនុស្សនៅជាប់នឹងឈ្មោះអ្នកប្រើប្រាស់របស់អ្នក។
2. ជ្រើសរើស ការកំណត់។




3. ចុច បន្ថែមលេខសម្គាល់ផ្ទាល់ខ្លួនថ្មី។
4. បញ្ចូលលេខសម្គាល់ផ្ទាល់ខ្លួនថ្មី។
5. បញ្ជាក់លេខសម្គាល់ផ្ទាល់ខ្លួន។
6. ជ្រើសរើស បន្ថែមលេខសម្គាល់ផ្ទាល់ខ្លួនថ្មី។



7. ជ្រើសរើស បាទ/ចាស ដើម្បីបញ្ជាក់លេខសម្គាល់ផ្ទាល់ខ្លួនថ្មី។

ពាក្យសម្ងាត់ត្រូវបានកំណត់ឡើងវិញ និងលេខសម្គាល់ផ្ទាល់ខ្លួន ត្រូវបានធ្វើបច្ចុប្បន្នភាព។




## ផ្លាស់ប្តូរលេខសម្គាល់ផ្ទាល់ខ្លួន

អ្នកអាចផ្លាស់ប្តូរលេខសម្គាល់ផ្ទាល់ខ្លួនរបស់អ្នកក្នុង OR PTC DCI នៅពេលណាក៏បាន។







1. ជ្រើសរើសរូបតំណាងមនុស្សនៅជាប់នឹងឈ្មោះអ្នកប្រើប្រាស់របស់អ្នក។
2. ជ្រើសរើស ការកំណត់។

3. ជ្រើសរើស ផ្លាស់ប្តូរលេខសម្គាល់ផ្ទាល់ខ្លួន។
4. បញ្ចូលពាក្យសម្ងាត់ OR PTC DCI របស់អ្នក។
5. ជ្រើសរើស ផ្ទៀងផ្ទាត់។
6. បញ្ចូលលេខសម្គាល់ផ្ទាល់ខ្លួនថ្មី។
7. បញ្ចូលលេខសម្គាល់ផ្ទាល់ខ្លួនថ្មីឡើងវិញ។
8. ជ្រើសរើស ផ្លាស់ប្តូរលេខសម្គាល់ផ្ទាល់ខ្លួន ដើម្បីរក្សាទុក។
9. ជ្រើសរើស បាទ/ចាស ដើម្បីបញ្ជាក់ការផ្លាស់ប្តូរលេខសម្គាល់ផ្ទាល់ខ្លួន។




10. បន្ទាប់មកអ្នកនឹងឃើញផ្ទាំងពណ៌បៃតងដែលបង្ហាញថា "លេខសម្គាល់ផ្ទាល់ខ្លួនត្រូវបានផ្លាស់ប្តូរដោយជោគជ័យ" ឥឡូវនេះ លេខសម្គាល់ផ្ទាល់ខ្លួនរបស់អ្នកត្រូវបានធ្វើបច្ចុប្បន្នភាពរួចហើយ ហើយមិនត្រូវការសកម្មភាពបន្ថែមទៀតទេ។
11. ជ្រើសរើស ទំព័រដើម ឬរូបតំណាង OR PTC DCI ដើម្បីត្រឡប់ទៅអេក្រង់ដើមវិញ។



## ផ្លាស់ប្តូរសំណួរសុវត្ថិភាព

អ្នកប្រហែលជាចង់ផ្លាស់ប្តូរសំណួរសុវត្ថិភាព ឬចម្លើយរបស់អ្នក។ សំណួរទាំងនេះត្រូវបានប្រើនៅពេលកំណត់ពាក្យសម្ងាត់របស់អ្នកឡើងវិញ។ សូមប្រាកដថាអ្នកជ្រើសរើសសំណួរ និងចម្លើយដែលអ្នកនឹងចងចាំ។




1. ជ្រើសរើសរូបតំណាងមនុស្សនៅជាប់នឹងឈ្មោះអ្នកប្រើប្រាស់របស់អ្នក។
2. ជ្រើសរើស ការកំណត់។
3. ជ្រើសរើសផ្ទាំង ផ្លាស់ប្តូរសំណួរសុវត្ថិភាព។
4. បញ្ចូលពាក្យសម្ងាត់បច្ចុប្បន្នរបស់អ្នក។
5. ជ្រើសរើស ផ្ទៀងផ្ទាត់។




6. ជ្រើសរើសសំណួរសុវត្ថិភាពពីបញ្ជីទម្លាក់ចុះ។
7. បញ្ចូលចម្លើយ។
8. ជ្រើសរើស បញ្ជូន ដើម្បីរក្សាទុកសំណួរសុវត្ថិភាព។



**ចំណាំ៖** លក្ខខណ្ឌតម្រូវនៃសំណួរសុវត្ថិភាព៖

- ចម្លើយចំពោះសំណួរសុវត្ថិភាពត្រូវតែមានយ៉ាងហោចណាស់ 5 តួអក្សរ
- ឈ្មោះអ្នកប្រើប្រាស់ ឬពាក្យសម្ងាត់ មិនអាចត្រូវបានប្រើប្រាស់ជាចម្លើយចំពោះសំណួរសុវត្ថិភាពទេ
- ប្រសិនបើចម្លើយចំពោះសំណួរសុវត្ថិភាពត្រូវបានរកឃើញនៅលើបញ្ជីពាក្យសម្ងាត់ដែលបានប្រើប្រាស់ទូទៅ អ្នកនឹងឃើញសារដូចខាងក្រោម៖
    - ចម្លើយដែលអ្នកបានផ្តល់ឱ្យត្រូវបានរកឃើញនៅលើបញ្ជីពាក្យសម្ងាត់ដែលបានប្រើប្រាស់ទូទៅ ហើយអាចទាយបានយ៉ាងងាយស្រួល។ ពិចារណាប្រើប្រាស់ពាក្យ ឬឃ្លាខុសគ្នា។
        - ប្រសិនបើអ្នកចង់បន្តប្រើប្រាស់ពាក្យ ឬឃ្លាដែលបានបញ្ចូល សូមចុច ទោះបីយ៉ាងណា ប្រើចម្លើយនេះ ប្រអប់ធីក។
        - ប្រសិនបើអ្នកចង់បញ្ចូលពាក្យ ឬឃ្លាខុសគ្នា គ្រាន់តែធ្វើបច្ចុប្បន្នភាពកន្លែងបំពេញចម្លើយដែលមានការឆ្លើយតបថ្មីរបស់អ្នកប៉ុណ្ណោះ។

9. បន្ទាប់មកអ្នកនឹងឃើញផ្ទាំងពណ៌បៃតងដែលបង្ហាញថា "សំណួរសុវត្ថិភាពត្រូវបានផ្លាស់ប្តូរដោយជោគជ័យ" ឥឡូវនេះ សំណួរសុវត្ថិភាពត្រូវបានធ្វើបច្ចុប្បន្នភាពរួចហើយ ហើយមិនត្រូវការសកម្មភាពបន្ថែមទៀតទេ។
10. ជ្រើសរើស ទំព័រដើម ឬរូបតំណាង OR PTC DCI ដើម្បីត្រឡប់ទៅអេក្រង់ដើមវិញ។




## ផ្លាស់ប្តូរអ៊ីមែល

អ្នកប្រហែលជាចង់ផ្លាស់ប្តូរអាសយដ្ឋានអ៊ីមែលរបស់អ្នកនៅលើឯកសារនៅក្នុង OR PTC DCI។

1. ជ្រើសរើសរូបតំណាងមនុស្សនៅជាប់នឹងឈ្មោះអ្នកប្រើប្រាស់របស់អ្នក។
2. ជ្រើសរើស ការកំណត់។
3. ជ្រើសរើសផ្ទាំង ផ្លាស់ប្តូរអ៊ីមែល។



4. អ៊ីមែលបច្ចុប្បន្នមានអ្នកប្រើហើយ។
5. បញ្ចូលអ៊ីមែលថ្មី។
6. បញ្ជាក់អ៊ីមែលថ្មី។




7. ជ្រើសរើស ផ្លាស់ប្តូរអ៊ីមែល ដើម្បីរក្សាទុកអ៊ីមែលថ្មី។
8. លេខកូដផ្ទៀងផ្ទាត់ត្រូវបានផ្ញើទៅកាន់គណនីអ៊ីមែលថ្មីដែលបានបញ្ចូល។ បញ្ចូលលេខកូដផ្ទៀងផ្ទាត់នៅទីនេះ។
9. ចុច ផ្លាស់ប្តូរអ៊ីមែល។



10. ជ្រើសរើស បាទ/ចាស ដើម្បីបញ្ជាក់ការផ្លាស់ប្តូរអ៊ីមែល។
11. បន្ទាប់មក ផ្ទាំងពណ៌បៃតងនឹងបង្ហាញថា "អ៊ីមែលត្រូវបានផ្លាស់ប្តូរដោយជោគជ័យ!" ឥឡូវនេះ អាសយដ្ឋានអ៊ីមែលរបស់អ្នកត្រូវបានធ្វើបច្ចុប្បន្នភាពរួចរាល់ហើយ ហើយ




មិនត្រូវការសកម្មភាពបន្ថែមទៀតទេ។

12. ជ្រើសរើស ទំព័រដើម ឬរូបតំណាង OR PTC DCI ដើម្បីត្រឡប់ទៅអេក្រង់ដើមវិញ។




## ផ្ទៀងផ្ទាត់លេខទូរសព្ទចល័ត

អ្នកត្រូវតែផ្ទៀងផ្ទាត់លេខទូរសព្ទចល័តរបស់អ្នកដើម្បីទទួលបានសារជាអក្សរពី OR PTC DCI។

1. ជ្រើសរើសរូបតំណាងមនុស្សនៅជាប់នឹងឈ្មោះអ្នកប្រើប្រាស់របស់អ្នក។
2. ជ្រើសរើស ការកំណត់។



3. ជ្រើសរើស ផ្ទាំងផ្ទៀងផ្ទាត់ទូរសព្ទចល័ត។
4. បញ្ចូលលេខទូរសព្ទចល័ត។
5. ជ្រើសរើស ធ្វើបច្ចុប្បន្នភាពលេខទូរសព្ទចល័ត។




6. ចុច ផ្ញើលេខកូដផ្ទៀងផ្ទាត់។



7. អ្នកនឹងទទួលបានសារជាអក្សរដែលមានលេខកូដផ្ទៀងផ្ទាត់តាមលេខទូរសព្ទចល័តដែលអ្នកបានបញ្ចូលនៅក្នុង OR PTC DCI។ បញ្ចូលលេខកូដនៅក្នុងប្រអប់ដែលមានដាក់ស្លាកថា "លេខកូដផ្ទៀងផ្ទាត់"។
8. ចុច ផ្ទៀងផ្ទាត់លេខទូរសព្ទចល័ត។




9. បន្ទាប់មកផ្ទាំងពណ៌បៃតងនឹងបង្ហាញថា "លេខទូរសព្ទចល័តរបស់អ្នកត្រូវបានផ្ទៀងផ្ទាត់"។ ឥឡូវនេះ លេខទូរសព្ទចល័តរបស់អ្នកត្រូវបានផ្ទៀងផ្ទាត់ ហើយមិនចាំបាច់មានសកម្មភាពបន្ថែមទៀតទេ។
10. ជ្រើសរើស ទំព័រដើម ឬរូបតំណាង OR PTC DCI ដើម្បីត្រឡប់ទៅអេក្រង់ដើមវិញ។




ប្រសិនបើអ្នកចង់ឈប់ទទួលសារជាអក្សរ សូមវាយពាក្យ “STOP” ផ្ញើត្រឡប់ទៅលេខដែលអ្នកបានទទួលសារ OR PTC DCI។

## ផ្លាស់ប្តូរឈ្មោះអ្នកប្រើប្រាស់

អ្នកប្រហែលជាចង់ផ្លាស់ប្តូរឈ្មោះអ្នកប្រើប្រាស់ OR PTC DCI របស់អ្នក។

1. ជ្រើសរើសរូបតំណាងមនុស្សនៅជាប់នឹងឈ្មោះអ្នកប្រើប្រាស់របស់អ្នក។
2. ជ្រើសរើស ការកំណត់។
3. ជ្រើសរើសផ្ទាំង ផ្លាស់ប្តូរឈ្មោះអ្នកប្រើប្រាស់។
4. បញ្ចូលឈ្មោះអ្នកប្រើប្រាស់ដែលអ្នកចង់បាននៅក្នុងប្រអប់ ឈ្មោះអ្នកប្រើប្រាស់ថ្មី។
5. ជ្រើសរើស ផ្លាស់ប្តូរឈ្មោះអ្នកប្រើប្រាស់ ដើម្បីរក្សាទុក។







6. ជ្រើសរើស បាទ/ចាស ដើម្បីបញ្ជាក់ការផ្លាស់ប្តូរ។



7. បន្ទាប់មកផ្ទាំងពណ៌បៃតងនឹងបង្ហាញថា "ឈ្មោះអ្នកប្រើប្រាស់ត្រូវបានផ្លាស់ប្តូរដោយជោគជ័យ!" ឥឡូវនេះ ឈ្មោះអ្នកប្រើប្រាស់របស់អ្នកត្រូវបានផ្លាស់ប្តូរហើយ។
8. ជ្រើសរើស ទំព័រដើម ឬរូបតំណាង OR PTC DCI ដើម្បីត្រឡប់ទៅអេក្រង់ដើមវិញ។

